# ព្រះរាជក្រម

នស/រកម/០៣១៧/០០៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៨៥/០១៥/២០១៧ កបធ.ច ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# វិសោធនកម្មច្បាប់ស្តីពីគណបក្ស

# នយោបាយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

ច្បាប់ស្តីពីគណបក្សនយោបាយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

-ចំណងជើងជំពូកទី៤ ត្រូវបានកែប្រែទៅជាជំពូកទី៤ថ្មី អង្គការនានា និងថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ ។

-ចំណងជើងជំពូកទី៩ ត្រូវបានកែប្រែទៅជាជំពូកទី៩ថ្មី វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ ។

-មាត្រា ៦ មាត្រា ១២ មាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៩ មាត្រា ៣៤ និងមាត្រាទាំងឡាយពីជំពូកទី ៩ ដល់ជំពូកទី ១១ ត្រូវបានកែប្រែដូចខាងក្រោម ៖

**មាត្រា ៦.-ថ្មី**

គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយ ដូចខាងក្រោម ៖

១- ធ្វើឲ្យមានអបគមន៍ ដែលនាំឲ្យអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី ។

២- ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។

៣- ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ ។

៤- បង្កើតកងកម្លាំងប្រដាប់អាវុធ ។

៥- ធ្វើការញុះញង់ដែលអាចនាំឲ្យមានការបែកបាក់ជាតិ ។

**មាត្រា ១២.-ថ្មី**

មានតែប្រជាពលរដ្ឋខ្មែរ ដែលមានអាយុយ៉ាងតិច ១៨ (ដប់ប្រាំបី)ឆ្នាំ និងមានសិទ្ធិពលរដ្ឋប៉ុណ្ណោះ ដែលអាចចូលជាសមាជិកគណបក្សនយោបាយបាន ។

**មាត្រា ១៧.-ថ្មី**

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឲ្យមានអង្គការដឹកនាំយ៉ាងតិចដូចខាងក្រោម ៖

១-មហាសន្និបាត ឬសមាជ ឬអង្គការសមមូល ។

២-ក្រុមប្រឹក្សាជាតិ ឬគណៈកម្មាធិការកណ្តាល ឬអង្គការសមមូល ។

៣-គណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូល ។

៤-គណៈកម្មាធិការអាជ្ញាកណ្តាល ឬគណៈកម្មាធិការត្រួតពិនិត្យ ឬគណៈកម្មាធិការវិវាទ ឬអង្គការសមមូល ។

ឈ្មោះអង្គការដឹកនាំរបស់គណបក្សនយោបាយគ្រប់ថ្នាក់នេះ អាចប្រែប្រួលអាស្រ័យទៅតាមការកំណត់របស់លក្ខន្តិកៈនៃគណបក្សនយោបាយនីមួយៗ ។

គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឲ្យមានប្រធាន និងអាចមានអនុប្រធានតាមការចាំបាច់ ។ ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ ត្រូវជ្រើសរើសដោយអនុវត្តតាមលក្ខន្តិកៈនៃ គណបក្សនយោបាយនីមួយៗ ។

អាណត្តិ ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗ ដូចមានចែងខាងលើនេះ ព្រមទាំងអង្គការដឹកនាំផ្សេងទៀតរបស់គណបក្សនយោបាយត្រូវកំណត់ក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ ។

## មាត្រា ១៨._ថ្មី

ពលរដ្ឋទាំងពីរភេទ ដែលមានសញ្ជាតិខ្មែរពីកំណើត និងមានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ អាចធ្វើជាប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬធ្វើជាសមាសភាពនៃអង្គការដឹកនាំ នៃគណបក្សនយោបាយបាន ។

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ មិនត្រូវជាបុគ្គលដែលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសឡើយ ។

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវបាត់បង់នូវតួនាទីរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម ៖

-សាមីខ្លួនទទួលមរណភាព ។

-សាមីខ្លួនបានសុំលាឈប់ជាលាយលក្ខណ៍អក្សរ ។

-សាមីខ្លួនត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសលើកលែងតែទោសនោះត្រូវបានលើកលែងទោសដោយព្រះមហាក្សត្រ ។

គណបក្សនយោបាយ ត្រូវចាត់នីតិវិធីដើម្បីជំនួសប្រធានគណបក្សនយោបាយដែលបាត់បង់តួនាទី ដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្នុងរយៈពេលយ៉ាងយូរ ៩០ (កៅសិប)ថ្ងៃ គិតពីថ្ងៃបាត់បង់តួនាទីនោះ ។

បទប្បញ្ញត្តិនេះ ក៏ត្រូវយកទៅអនុវត្តផងដែរចំពោះបុគ្គលដែលមានតួនាទី ឬសិទ្ធិអំណាចប្រហាក់ប្រហែលទៅនឹងប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណៈកម្មា-

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬ គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ។

## មាត្រា ១៩._ថ្មី

ក្នុងរយៈពេលយ៉ាងយូរ ១៨០ (មួយរយប៉ែតសិប) ថ្ងៃ បន្ទាប់ពីគណបក្សនយោបាយត្រូវបាន បង្កើតឡើងស្របតាមមាត្រា ៩ នៃច្បាប់នេះ គណបក្សនយោបាយនោះត្រូវស្នើសុំចុះបញ្ជីនៅក្រសួង មហាផ្ទៃ ដើម្បីទទួលបានសុពលភាព និងអាចធ្វើសកម្មភាពបានដោយស្របច្បាប់ក្នុងឋានៈជានីតិបុគ្គល ដោយត្រូវមានសមាជិកយ៉ាងតិច ៤០០០ (បួនពាន់) នាក់ និងត្រូវបំពេញបែបបទ និងលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់នេះ ។

គណបក្សនយោបាយដែលមិនទទួលបានការចុះបញ្ជី ស្របតាមបទប្បញ្ញត្តិនៃជំពូកនេះ មិន អាចធ្វើសកម្មភាពនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

## មាត្រា ២៥._ថ្មី

គណបក្សនយោបាយណា ដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមឲ្យចុះបញ្ជី គណបក្សនយោបាយ ដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះមានសិទ្ធិ ប្តឹងទៅតុលាការកំពូល ។

តុលាការកំពូលត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ពាក្យបណ្តឹងរបស់សាមីគណបក្សនយោបាយនោះ ។

ក្រោយពីបានទទួលសេចក្តីសម្រេចរបស់តុលាការកំពូលដែលសម្រេចលើភាពត្រឹមត្រូវនៃខ្លឹមសារ នៃសំណុំឯកសាររបស់គណបក្សនយោបាយនោះ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជីគណបក្សនយោបាយ នោះភ្លាម តាមការកំណត់ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

## មាត្រា ២៦._ថ្មី

គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ ត្រូវបញ្ជូនទៅក្រសួងមហាផ្ទៃនូវបញ្ជីឈ្មោះ ប្រធាន និងអនុប្រធាន នៃគណបក្សនយោបាយ ក្នុងករណីដែលមានអនុប្រធាន និងសមាសភាព នៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេប ដែលមាន បិទរូបថតទំហំ ០៤ (បួន) គុណនឹង ០៦ (ប្រាំមួយ) ។

ការផ្លាស់ប្តូរប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណៈកម្មាធិការ នាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

អចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់សមាសភាពថ្មី ដែលមានបិទរូបថតទំហំ ០៤ (បួន) គុណនឹង ០៦ (ប្រាំមួយ) ។

គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ អាចប្តូរឈ្មោះ សញ្ញាសម្គាល់ ទីស្នាក់ការកណ្តាល កែប្រែគោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ ឬធ្វើវិសោធនកម្មលើលក្ខន្តិកៈបានស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយខ្លួន។ ក្នុងករណីនេះគណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃដោយភ្ជាប់មកជាមួយនូវសំណុំឯកសារថ្មីដែលកែប្រែរួចហើយ ។

## មាត្រា ២៩.-ថ្មី

គណបក្សនយោបាយត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយ ពីស្ថាប័នរដ្ឋ សមាគម អង្គការមិនមែនរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ វិទ្យាស្ថានសាធារណៈ លើកលែងតែករណីដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ។

គណបក្សនយោបាយត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះតាមរូបភាពណាក៏ដោយ ពីស្ថាប័នបរទេស ក្រុមហ៊ុនបរទេស ជនបរទេស ឬអង្គការដែលមានប្រភពហិរញ្ញប្បទានពីបរទេស ។

## មាត្រា ៣៤.-ថ្មី

គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សនយោបាយណាមួយបានឡើយ លើកលែងគណបក្សនោះ ត្រូវបានរំលាយដោយតុលាការ ។

## មាត្រា ៣៨.-ថ្មី

គ្រប់គណបក្សនយោបាយទាំងអស់ត្រូវគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាណាចក្រកម្ពុជា ។

ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តខុសទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃអាចចាត់វិធានការដូចខាងក្រោម ៖

-ចេញលិខិតជូនដំណឹងឲ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវក្នុងរយៈពេលមួយជាកំណត់ ។

-ធ្វើការព្រមានជាលាយលក្ខណ៍អក្សរ និងចាត់វិធានការបញ្ឈប់សកម្មភាពខុសច្បាប់ ក្នុងករណីចាំបាច់ ។

-សម្រេចផ្អាកសកម្មភាពរបស់គណបក្សនយោបាយនោះជាបណ្តោះអាសន្នក្នុងរយៈពេលមួយជាក់ណត់ ។

-ប្តឹងទៅតុលាការកំពូល ដើម្បីរំលាយគណបក្សនយោបាយនោះ ក្នុងករណីកំហុសមានលក្ខណៈធ្ងន់ធ្ងរ ។

## មាត្រា ៣៩._ថ្មី

ត្រូវផាកពិន័យជាប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន) រៀល ដោយក្រសួងមហាផ្ទៃ ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣១ នៃច្បាប់នេះ ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀត ផាកពិន័យជាប្រាក់ទ្វេមួយជាពីរ ហើយក្រសួងមហាផ្ទៃអាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្ន ក្នុងរយៈពេលមួយជាកំណត់ ។

## មាត្រា ៤០._ថ្មី

គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងមហាផ្ទៃ ចំនួន ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។ ក្នុងករណីវិភាគទានដែលគណបក្សនយោបាយបានទទួលដោយល្មើសនឹងមាត្រា ២៩ ថ្មី នៃច្បាប់នេះ មានតម្លៃលើសពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃតម្លៃនៃវិភាគទាននោះ ។ ក្រសួងមហាផ្ទៃ អាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្នក្នុងរយៈពេលមួយជាកំណត់ ។

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀតត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃប្រាក់ពិន័យលើកមុន ហើយក្រសួងមហាផ្ទៃអាចប្តឹងរំលាយគណបក្សនយោបាយនោះទៅតុលាការកំពូល ។

## មាត្រា ៤១._ថ្មី

ត្រូវផាកពិន័យជាប្រាក់ចំនួន ៣ ០០០ ០០០ (បីលាន) រៀល ដោយក្រសួងមហាផ្ទៃ ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ និងកថាខណ្ឌទី ២ មាត្រា ១៥ នៃច្បាប់នេះ ។

## មាត្រា ៤២._ថ្មី

ត្រូវពិន័យជាប្រាក់ចំនួន ១០ ០០០ ០០០ (ដប់លាន) រៀល ដល់ ២០ ០០០ ០០០ (ម្ភៃលាន) រៀល និង/ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ០១(មួយ) ខែ ដល់ ០១(មួយ) ឆ្នាំ ចំពោះជនណាដែលបានប្រព្រឹត្តករណីណាមួយដូចខាងក្រោម ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

១-បន្តគ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដែលក្រសួងមហាផ្ទៃមិនយល់ព្រមឲ្យចុះបញ្ជីគណបក្សនយោបាយ ។

២-បន្តគ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដែលតុលាការបានសម្រេចរំលាយជាស្ថាពរ។

៣-គ្រប់គ្រង ឬដឹកនាំគណបក្សនយោបាយដោយមិនបានសុំចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ក្នុងរយៈពេលលើសពី ១៨០ (មួយរយប៉ែតសិប)ថ្ងៃ គិតចាប់ពីថ្ងៃធ្វើការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការបណ្តោះអាសន្នដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ។

៤-នៅតែបន្តធ្វើសកម្មភាពក្នុងនាមគណបក្សនយោបាយ ទោះជាមានសេចក្តីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះក៏ដោយ ។

៥-នៅតែបន្តបើកទីស្នាក់ការគណបក្សនយោបាយខ្លួន ទោះជាមានសេចក្តីសម្រេចស្ថាពររបស់តុលាការសម្រេចរំលាយគណបក្សនយោបាយនោះក៏ដោយ ។

## មាត្រា ៤៣.–ថ្មី

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាទៅតុលាការកំពូលក្នុងអំឡុងពេល ៣០(សាបសិប)ថ្ងៃ គិតពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចនេះ ។ ក្នុងអំឡុងពេលនៃការប្តឹងតវ៉ា និងអំឡុងពេលនៃការដោះស្រាយបណ្តឹងតវ៉ា សេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ មិនមានអានុភាពអនុវត្តឡើយ លើកលែងតែសេចក្តីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយជាបណ្តោះអាសន្ន ។

## មាត្រា ៤៤.–ថ្មី

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៦ ថ្មី និងមាត្រា ៧ នៃច្បាប់នេះ តុលាការអាចសម្រេចដូចខាងក្រោម ៖

-ផ្អាកសកម្មភាពគណបក្សនយោបាយនោះក្នុងរយៈពេលមិនលើសពី ៥ ឆ្នាំ ។

-រំលាយគណបក្សនយោបាយនោះ ។

## មាត្រា ៤៥.–ថ្មី

តុលាការដែលមានសមត្ថកិច្ច ដើម្បីពិនិត្យលើបណ្តឹងនានាដោយអនុវត្តតាមច្បាប់នេះ គឺតុលាការកំពូល ។ ដោយឡែកចំពោះមាត្រា ៤២ ថ្មី នៃច្បាប់នេះ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

តំណាងមហាអយ្យការអមតុលាការកំពូលត្រូវចូលរួមសុំឲ្យមានការគោរពច្បាប់ នៅក្នុងពេលដែលមានបណ្តឹងដាក់ជូនតុលាការកំពូលពិនិត្យ ។

ក្នុងករណីដែលគណបក្សនយោបាយត្រូវបានរំលាយ តុលាការអាចសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំនៃគណបក្សនយោបាយនោះសម្រាប់រយៈពេល ០៥(ប្រាំ) ឆ្នាំបាន ។

តុលាការកំពូលត្រូវសម្រេចសេចក្ដីលើអង្គហេតុ និងអង្គច្បាប់ ដោយសភាពេញអង្គ ។ សាលដីការបស់តុលាការកំពូលជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ។

## មាត្រា ៤៦._ថ្មី

ការអនុវត្តជំពូកនេះ មិនរារាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិដែលចែងក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ ។

## មាត្រា ៤៧._ថ្មី

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី៨ (នីតិវិធីប្រតិបត្តិ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្ដីសម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ ។

## មាត្រា ៤៨._ថ្មី

បន្ទាប់ពីច្បាប់នេះចូលជាធរមាន គណបក្សនយោបាយទាំងអស់ដែលត្រូវបានបង្កើត និងបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបន្តសុពលភាព និងអាចធ្វើសកម្មភាពស្របតាមច្បាប់នេះ និងច្បាប់ជាធរមានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែគណបក្សនយោបាយទាំងនេះ ត្រូវបំពេញសំណុំបែបបទធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិ នៃច្បាប់នេះក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

## មាត្រា ៤៩._ថ្មី (មាត្រា៤៤ ចាស់)

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

## មាត្រា ៥០._ថ្មី (មាត្រា៤៥ ចាស់)

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រាពីរ.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ២០១៧

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសបញ្ជាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

នស/រកម.០៣១៧/០០៣.៤២២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ២៥៨ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើម សម្រាប់ជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខា**